# នមស្សការ បទសរភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្ដា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុរឱ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន ធ្វើតាមលំអានបានក្ដីសុខ ។
ឥតមានសុខណាស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្ដីសុខកើតមានព្រោះធម៌ស្ងប់។
សូមថ្វាយបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមទាំងត្រៃរ័ត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធិតាងអង្គព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា ឱ្យបានសុខាតរៀងទៅ ។

ព្រះរាជនិពន្ធសម្ដេចព្រះសង្ឃរាជ ព្រះសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត

## នមស្សការព្រះរតនត្រៃ

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះ ព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។ (កាបថ្វាយបង្គំម្តង)

## នមស្សការព្រះរតនត្រៃ បទព្រហ្មគីតិ

### យោ សន្និសិន្នោ វរពោធិមូលេ
### មារំ សសេនំ មហតី វិជេយ្យោ
### សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ
### លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

វីរអង្គព្រះសម្ពុទ្ធ ប្រសើរផុតអង្គឯណា
គង់ក្រោមម្លប់រុក្ខា ពោធិព្រឹក្សជាមង្គល ។
ទ្រង់ផ្ចាញ់នូវមារា ឱ្យបរាជ័យទាំងពល
ហើយព្រះអង្គបានដល់ នូវត្រាស់ដឹងជាសាស្តា ។
មានព្រះបញ្ញាញាណ ជ្រាបពុំមានសល់ត្រង់ណា
ខ្ញុំម្ចាស់សូមវន្ទា ព្រះអង្គនោះដោយគោរព ។

### អដ្ឋង្គិការិយបថោ ជនានំ
### មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្ទិករោ បណីតោ
និយ្យានិកោ តំ បនមាមិ ធម្មំ ។

ព្រះធម៌ប្រកបអង្គ ជាផ្លូវត្រង់ប្រាំបីណា
ជាគន្លងលោកា ត្រេចយាត្រាទៅនិព្វាន ។
ញុំាងជនដែលប្រាថ្នា ឱ្យយាត្រាចូលទៅបាន
ព្រះធម៌នេះកល្យាណ រម្ងាប់បានភ្លើងទុក្ខា ។
ជាធម៌ឧត្តមផង នាំសត្វឆ្លងចាកសង្សារ
ខ្ញុំសូមនមស្សការ ព្រះធម៌នោះដោយគោរព។

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បនមាមិ សង្ឃំ ។

ព្រះសង្ឃអង្គបរិសុទ្ធ ប្រសើរផុតក្នុងលោកា
គួរដល់ទានទក្ខិណា មានឥន្ទ្រិយរម្ងាប់ហើយ ។
លះមន្ទិលគឺកិលេស អស់គ្មានសេសសល់តិចឡើយ
ជាព្រះសង្ឃដល់ហើយ សម្រេចដោយគុណគួរគាប់ ។
អាសវៈលះស្រឡះ លោកជាព្រះខីណាស្រព
ខ្ញុំម្ចាស់សូមគោរព ថ្វាយបង្គំព្រះសង្ឃនោះ ។

# នមស្សការព្រះរតនត្រៃ ទាំងបីកាល
## បទបឋ្យាវត្ត

យេ ច ពុទ្ធា អតីតា ច　　យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា　　អហំ វន្ទាមិ សព្វទា ។
ព្រះពុទ្ធទាំងឡាយជាម្ចាស់អង្គណា　　ដែលបានត្រាស់ជាព្រះពុទ្ធជិនស្រី
ព្រះអង្គនិព្វានកន្លងទៅក្តី　　ខ្ញុំសូមវន្ទីព្រះនោះផង ។
ព្រះពុទ្ធទាំងឡាយជាម្ចាស់អង្គណា　　នឹងបានត្រាស់ជាព្រះពុទ្ធអង្គ
ដែលមានក្នុងកាលខាងមុខនោះផង　　សូមថ្វាយបំណងបង្គំទុកវែង ។
ព្រះពុទ្ធទាំងឡាយជាម្ចាស់អង្គណា　　បានត្រាស់ហើយជាព្រះពុទ្ធជាក់ស្តែង
ដែលមានក្នុងភទ្រកប្បនេះឯង　　ខ្ញុំសូមសំដែងហត្ថថ្វាយបង្គំ ។

យេ ច ធម្មា អតីតា ច　　យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា　　អហំ វន្ទាមិ សព្វទា ។
ព្រះធម៌ព្រះពុទ្ធជាម្ចាស់អង្គណា　　ដែលបានត្រាស់ជាព្រះពុទ្ធជិនស្រី
ព្រះអង្គនិព្វានកន្លងទៅក្តី　　ខ្ញុំសូមវន្ទីព្រះអង្គនោះផង ។
ព្រះធម៌ព្រះពុទ្ធជាម្ចាស់អង្គណា　　នឹងបានត្រាស់ជាព្រះពុទ្ធអង្គ
ដែលមានក្នុងកាលខាងមុខនោះផង　　សូមថ្វាយបំណងបង្គំទុកវែង ។
ព្រះធម៌ទាំងឡាយជាម្ចាស់អង្គណា　　បានត្រាស់ហើយជាព្រះពុទ្ធជាក់ស្តែង
ដែលមានក្នុងភទ្រកប្បនេះឯង　　ខ្ញុំសូមសំដែងហត្ថថ្វាយបង្គំ ។

យេ ច សង្ឃា អតីតា ច　　យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា　　អហំ វន្ទាមិ សព្វទា ។
ព្រះសង្ឃទាំងឡាយនៃព្រះទសពល　　សម្រេចមគ្គផលនិព្វានទៅក្តី
ព្រះសង្ឃទាំងឡាយនៃព្រះជិនស្រី　　នឹងជាព្រះខីណាស្រពប្រាកដ ។

ព្រះសង្ឃទាំងឡាយព្រះតថាគត ដែលលោករំលត់កិលេសឥតសល់
ហើយបានសំរេចនូវមគ្គនឹងផល មានក្នុងមណ្ឌលភទ្រកប្បនេះឯង ។
ខ្ញុំសូមបង្គំសង្ឃគ្រប់កន្លែង ដែលជាគម្លែងសង្ឃក្នុងសាសនា
សូមមានសួស្តីសិរីសុខា គ្រប់កាលវេលាដល់ខ្ញុំនោះហោង ។

## នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ
## ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

វត្ថុដទៃជាទីពឹងខ្លួន មិនមានមាំមួនដល់ខ្ញុំឡើយណា
មានតែព្រះពុទ្ធដែលខ្ញុំជ្រះថ្លា ជាទីពឹងអាត្មាប្រសើរពេកក្រៃ ។
សូមមានមង្គលប្រសើរថ្លាថ្លៃ ទាំងយប់ទាំងថ្ងៃដល់ខ្ញុំករុណា
សូមបានផុតភ័យទាំងអស់គ្រប់គ្នា សព្វកាលវេលាតទៅមុខហោង ។

## នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ
## ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

វត្ថុដទៃជាទីពឹងខ្លួន មិនមានមាំមួនដល់ខ្ញុំឡើយណា
មានតែព្រះធម៌ដែលខ្ញុំជ្រះថ្លា ជាទីពឹងអាត្មាប្រសើរពេកក្រៃ ។
សូមមានមង្គលប្រសើរថ្លាថ្លៃ ទាំងយប់ទាំងថ្ងៃដល់ខ្ញុំករុណា
សូមបានផុតភ័យទាំងអស់គ្រប់គ្នា សព្វកាលវេលាតទៅមុខហោង ។

## នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ
## ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

វត្ថុដទៃជាទីពឹងខ្លួន មិនមានមាំមួនដល់ខ្ញុំឡើយណា
មានតែព្រះសង្ឃដែលខ្ញុំជ្រះថ្លា ជាទីពឹងអាត្មាប្រសើរពេកក្រៃ ។
សូមមានមង្គលប្រសើរថ្លាថ្លៃ ទាំងយប់ទាំងថ្ងៃដល់ខ្ញុំករុណា

សូមបានផុតភ័យទាំងអស់គ្រប់គ្នា សព្វកាលវេលាតទៅមុខហោង ។

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ
ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

សូមថ្វាយបង្គំធូលីព្រះបាទ នៃព្រះលោកនាថប្រសើរថ្លៃថ្លា
ដោយត្បូងនៃខ្ញុំសូមព្រះពុទ្ធា អត់នូវទោសានុទោសឱ្យទាន ។
ដែលខ្ញុំព្រះករុណាភ្លាំងភ្លាត់វិញ្ញាណ ហើយធ្វើបំពានលើព្រះពុទ្ធនោះ
ខ្ញុំសូមព្រះពុទ្ធជាម្ចាស់សង្គ្រោះ អត់នូវទោសនោះដល់ខ្ញុំករុណា ។

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ
ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។

សូមថ្វាយបង្គំព្រះធម៌ទាំងពីរ នៃព្រះមុនីប្រសើរថ្លៃថ្លា
ដោយត្បូងនៃខ្ញុំសូមព្រះធម្មា អត់នូវទោសានុទោសឱ្យទាន ។
ដែលខ្ញុំព្រះករុណាភ្លាំងភ្លាត់វិញ្ញាណ ហើយធ្វើបំពានលើព្រះធម៌នោះ
ខ្ញុំសូមព្រះធម៌ជាម្ចាស់សង្គ្រោះ អត់នូវទោសនោះដល់ខ្ញុំករុណា ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ
សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ។

សូមថ្វាយបង្គំព្រះសង្ឃទាំងពីរ នៃព្រះមុនីប្រសើរថ្លៃថ្លា
ដោយត្បូងនៃខ្ញុំសូមព្រះសង្ឃា អត់នូវទោសានុទោសឱ្យទាន ។
ដែលខ្ញុំព្រះករុណាភ្លាំងភ្លាត់វិញ្ញាណ ហើយធ្វើបំពានលើព្រះសង្ឃនោះ
ខ្ញុំសូមព្រះសង្ឃជាម្ចាស់សង្គ្រោះ អត់នូវទោសនោះដល់ខ្ញុំករុណា ។

# នមស្ការចំពោះព្រះសម្ពុទ្ធ២៨ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ    វន្ទេ មេធង្ករំ មុនី
សរណង្ករំ មុនី វន្ទេ   ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ   អនោមទស្សី មុនិ នមេ
វន្ទេ បទុមសម្ពុទ្ធំ   វន្ទេ នារទនាយកំ
បទុមុត្តរំ មុនី វន្ទេ   វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ   បិយទស្សី មុនី នមេ
អត្ថទស្សី មុនី វន្ទេ   ធម្មទស្សី មុនី នមេ
វន្ទេ សិទ្ធត្ថសត្ថារំ   វន្ទេ តិស្សមហាមុនី
វន្ទេ ផុស្សមហាវីរំ វន្ទេ វិបស្សិនាយកំ
សិខី មហាមុនី វន្ទេ   វន្ទេ វេស្សភុនាយកំ
កកុសន្ធំ មុនី វន្ទេ   វន្ទេ កោនាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ   វន្ទេ គោតមនាយកំ
អដ្ឋវីសតិមេ ពុទ្ធេ   និព្វានាមតទាយកា
នមេ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ។

ខ្ញុំសូមបង្គំព្រះបរមសម្ពុទ្ធ    មាននាមប្រាកដព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំព្រះបរមបវរ    ព្រះមេធង្ករជាសម្ពុទ្ធា ។
សូមក្រាបបង្គំប្រណម្យវន្ទា    នូវព្រះភគវាព្រះសរណង្ករ
សូមថ្វាយបង្គំព្រះទីបង្ករ    មានញាណបវរបារមីពោរពេញ ។

| | |
|---|---|
| សូមថ្វាយបង្គំនូវព្រះកោណ្ឌញ្ញ | ព្រះអង្គបំពេញធម៌ជាកុសល |
| ខ្ញុំសូមបង្គំនូវព្រះទសពល | ព្រះនាមមង្គលជាសម្ពុទ្ធៈ ។ |
| ខ្ញុំសូមបង្គំប្រណម្យគារវៈ | ព្រះនាមសុមនៈសម្មាសម្ពុទ្ធ |
| ខ្ញុំសូមបង្គំព្រះបរមសុគត | ព្រះនាមប្រាកដព្រះរេវតៈ ។ |
| ខ្ញុំសូមបង្គំព្រះបរមពុទ្ធៈ | មានញាណសោភៈព្រះនាមសោភិត |
| ខ្ញុំសូមបង្គំប្រណម្យប្រណិត | ឆ្ពោះព្រះវិជិតអនោមទស្សី ។ |
| ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសី | ចំពោះព្រះមុនីព្រះនាមបទុម |
| ខ្ញុំសូមឱនកាយថ្វាត់ថ្វាយបង្គំ | ចំពោះព្រះបរមព្រះនាមនារទៈ ។ |
| សូមថ្វាយបង្គំព្រះបទុមុត្តរៈ | មានញាណសោភវរពុទ្ធោ |
| ខ្ញុំសូមបង្គំនូវព្រះភគវា | ទ្រង់ព្រះនាមាសុមេធសម្ពុទ្ធ ។ |
| ខ្ញុំសូមបង្គំប្រណម្យក្រាបលុត | ឆ្ពោះព្រះសម្ពុទ្ធព្រះនាមសុជាត |
| ខ្ញុំសូមបង្គំប្រណម្យអភិវាទ | ឆ្ពោះព្រះមុនីនាថបិយទស្សី ។ |
| ខ្ញុំសូមបង្គំឆ្ពោះព្រះជិនស្រី | អត្ថទស្សីបារមីខ្ពង់ខ្ពស់ |
| ខ្ញុំសូមបង្គំឆ្ពោះព្រះទ្រង់យស | ព្រះនាមចំពោះធម្មទស្សី ។ |
| ខ្ញុំសូមបង្អោនលំទោនសិរសី | បង្គំជិនស្រីព្រះនាមសិទ្ធត្ថ |
| ខ្ញុំសូមបង្គំនូវព្រះមុនីរ័តន៍ | ព្រះនាមប្រាកដតិស្សសាស្តា ។ |
| ខ្ញុំសូមបង្គំនូវព្រះសម្មា- | សម្ពុទ្ធនាមថាផុស្សៈមុនី |
| ខ្ញុំសូមបង្គំប្រណម្យអញ្ជលី | ឆ្ពោះព្រះមុនីព្រះនាមវិបស្សី ។ |
| សូមថ្វាយបង្គំបរមជិនស្រី | ព្រះនាមសិខីសរពេជ្ញពុទ្ធា |
| ខ្ញុំសូមឱនកាយក្រាបថ្វាយវន្ទា | ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ ។ |
| ខ្ញុំសូមបង្គំលើកហត្ថទាំងគូ | ឆ្ពោះព្រះជាគ្រូនាមកកុសន្ធៈ |
| ខ្ញុំសូមបង្គំប្រណម្យគារវៈ | ឆ្ពោះព្រះពុទ្ធកោនាគមនោ ។ |
| ខ្ញុំសូមឱនកាយវាចាទន់ទោរ | បង្គំពុទ្ធោព្រះនាមកស្សបៈ |
| ខ្ញុំសូមលំទោនបង្អោនសិរៈ | ជាទីគារវៈព្រះនាមគោត្តម ។ |
| គំរប់ម្ភៃប្រាំបីព្រះបរម | សម្ពុទ្ធជាធំកំពូលលោកា |
| ទូទាំងត្រៃភពជាម្លប់សាខា | មនុស្សទេវតាមារព្រហ្មទាំងឡាយ ។ |

ដែលបានចូលជ្រកក្រោមម្លប់ព្រះឆាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខក្នុងស្ថានសួគ៌ា ឬឋានព្រហ្មានិងព្រះនិញ្វន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធានជាយាននាំសត្វ
តេជៈយើងខ្ញុំប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរ័ត្នគ្រប់ៗព្រះអង្គ ។
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គម្ភៃប្រាំបី
ខ្ញុំសូមអានុភាពពីព្រះជិនស្រី ម្ភៃប្រាំបីព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ព្រះអង្គសំដែង ទាំងព្រះគម្ភែងសង្ឃជាសាវ័ក
សូមសុខចំរើនកើតឡើងថ្នាក់ កុំឱ្យមានអាក់រៀងរាល់ជាតា ។
សូមឱ្យខ្ញុំបានដល់ឋានទេវតា ដូចក្ដីប្រាថ្នាកុំបីឃ្លៀងឃ្លាត ។
មានព្រះនិញ្វនជាអវសានជាតិ កុំឱ្យខ្ញុំឃ្លាតពីនិញ្វនហោង ។

## គាថាប្រារព្ធមាឃបូជា

មាឃនក្ខត្តយុត្តាយ បុណ្ណាយ បុណ្ណមាយ យោ
អរហំ សម្មាសម្ពុទ្ធោ ភគវា គោតមវ្ហយោ
សុទ្ធានន្តទយោ ញាណោ សត្ថា លោកេ អនុត្តរោ
វិហរន្តោ រាជគហេ មគធានំ គិរិព្វជេ
វិហារេ វេឡុវនេ ច កលន្ទកនិវាបិយេ
សង្ឃស្ស សន្និបាតម្ហិ ឧត្តមេ ចតុរង្គិកេ
អឌ្ឍតេលសេហិភិក្ខូ សគេហិ បរិវារិតោ
តីហិ គាថាហិ សង្ខិប្បំ សព្វំ ពុទ្ធាន សាសនំ
សមោសារេហិ ឱវាទំ បាតិមោក្ខំ អនុត្តរំ
តមេវម្ហតសម្ពុទ្ធំ សខីណាសវសាវកំ
ចិរកាលមតីតម្បិ បសាទេន អនុស្សរំ
អយម្បិ បរិសាសព្វា បសន្នា ធម្មគាមិនី

**សម្បត្តា តាទិសំ តាសំ  សុនក្ខត្តំ សមុជ្ជលំ**
**ទីបច្ឆបាទិសក្ការេ  អភិសជ្ជ យថាពលំ**
**តេហិ បូជេ តទេហជ្ជ  តុដ្ឋា ឥធ សមាគតា**
**អភិវន្ទ តំ បូជេតិ  ភគវន្តំ សសាវកំ**
**កាលេន សម្មុខី ភូតំ  អតីតារម្មណត្តនា**
**ឱសារេន្តំ បាតិមោក្ខំ  វិសុទ្ធត្ថមុបោសថេ**
**ឥតោ ជេន សុប្បញ្ញេន  សោត្ថិ ហោតុ សទាបិ នោ**
**សាសនំ សត្ថុ អម្ហាកំ  ចិរ ទិប្បតុ តាទិនោតិ ៗ**

ថ្ងៃនេះតិថីពេញបូណ៌មី  ខែមាឃប្រពៃឱកាសថ្លៃថ្លា
ពន្លឺរស្មីនៃព្រះចន្ទ្រា  ស្រឡះមេឃាភ្លឺចាំងបរិសុទ្ធ ។
ត្រូវចំនឹងថ្ងៃសាវ័កសន្និបាត  មកស្តាប់ឱវាទនៃព្រះសម្ពុទ្ធ
ព្រះអង្គប្រសើរវិសេសបំផុត  មានធម៌បរិសុទ្ធិលើសអស់លោកា។
ចំនួនយ៉ាងច្រើនដ៏ឱឡារិក  ឥតណាត់រំលឹកនូវពេលវេលា ។
មួយពាន់ពីររយហាសិបព្រះអង្គ  បានមកផ្ចិតផ្ចង់ប្រជុំជួបគ្នា
ក្នុងសំណាក់នៃព្រះអង្គសាស្តា  ក្នុងទីមហាវត្តវេឡុវ័ន ។
កលន្ទកនិវាបស្ថាន  ជាទីក្រៀមក្សាន្តដ៏មានសោភ័ណ
នៅក្រុងរាជគ្រឹះនាពេលសាយ័ណ្ហ  សីមាខេត្តខ័ណ្ឌមគធរដ្ឋ ។
ទីបីព្រះសង្ឃសាវ័កទាំងនោះ  ឯហិភិក្ខុយ៉ាងពិតប្រាកដ
លោកសុទ្ធតែបានឧបសម្ប័ទ  សម្រេចអរហត្តក្ស័យចាកតណ្ហា ។
វីអង្គទីបួនព្រះភិក្ខុសង្ឃ  សាវ័កគ្រប់អង្គជាអរហន្តា
សម្រេចនូវផ្លូវបដិសម្ភិទា  និងអភិញ្ញាប្រាំមួយទាំងអស់ ។
សាវ័កសន្និបាតគឺមានលក្ខណៈ  ព្រះពុទ្ធទ្រង់ត្រាស់សំដែងឱវាទ
ការរៀបប្រជុំសាវ័កបែបនេះ  ជាកិច្ចពិសេសនៃព្រះមុនីនាថ
ហៅថា " ចតុរង្គសន្និបាត "  បានស្តាប់ឱវាទព្រះតថាគត ។
ប្រជុំប្រកបដោយអង្គបួនហ្នឹង  បណ្ឌិតបានដឹងមានតែម្តងគត់

ក្នុងសម័យកាលនៃព្រះសម្ពុទ្ធ  ជាសព្វញ្ញុតព្រះនាមគោតម ។
សំដែងឱវាទប្បាដិមោក្ខ  គាថាប្រយោគធម៌ដ៏ឧត្តម
ដើម្បីគោរពឱ្យបានក្រិត្យក្រម  ឱ្យបានស្អាតស្អំក្នុងពុទ្ធសាសនា ។
ក្នុងថ្ងៃនោះដែរតែងតាំងរៀបចំ  សាវ័កឆ្វេងស្តាំអមព្រះសាស្តា
ព្រះសារីបុត្តកំពូលប្រាជ្ញា  ព្រះមោគ្គលានណាកំពូលឫទ្ធី ។
មានហេតុមួយទៀតអស្ចារ្យពេកក្រៃ  តិថីនៃថ្ងៃពេញបូណ៌មី
ខែមាឃនោះដែរព្រះពុទ្ធជិនស្រី  សម្រេចព្រះទ័យកំណត់សង្ខារ ។
នៅបីខែទៀតនឹងរំលត់ខន្ធ  ព្រះអង្គចូលកាន់និព្វានពិតណា
គំរប់ព្រះជន្មប៉ែតសិបវស្សា  ទុកព្រះសាសនាយ៉ាងល្អពេកក្រៃ ។
តិថីថ្ងៃនេះយើងចូរចាំជាក់  ជាឧបលក្ខិតសម័យ
ពុទ្ធបរិស័ទអ្នកមាននិស្ស័យ  បង្គំថ្វាត់ថ្វាយដល់ព្រះភគវា ។
យើងខ្ញុំទាំងអស់ជាពុទ្ធបរិស័ទ  បានមកប្រណិប័តន៍ប្រជុំគ្នីគ្នា
រៀបគ្រឿងប្រដាប់សក្ការបូជា  មានទានធូបផ្កាលំឧតផ្ចិតផ្ចង់ ។
ដោយចិត្តជ្រះថ្លាយ៉ាងច្បាស់ប្រត្យក្ស  ជំនឿជឿជាក់ក្នុងព្រះពុទ្ធអង្គ
មានព្រះពុទ្ធរូបតាំងស្នងព្រះអង្គ  ទ្រង់ស្តេចមកគង់ប្រថាប់ថ្លៃថ្លា ។
យើងខ្ញុំសូមថ្វាយសក្ការបូជា  គោរពវន្ទាព្រះត្រៃរតនា
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃមហិមា  ដោយកាយវាចានិងចិត្តប្រពៃ ។
បពិត្រព្រះពុទ្ធព្រះទសពល  វិជិតនិម៌លនាមាភិធេយ្យ
មានឫទ្ធិតេជៈគុណព្រះបារមី  ល្បាញល្បីសុសសាយក្នុងលោកត្រៃភព។
ទ្រង់ជាបូជារហបុគ្គល  បញ្ញាញាណយល់ដឹងទាំងគ្រប់សព្វ
ព្រះធម៌ព្រះអង្គដ៏វិសេសគាប់  ប្រព្រឹត្តបានស្ងប់រម្ងាប់ទុក្ខបាន ។
ព្រះពុទ្ធជាគ្រូនៃមនុស្សទេព្តា  ឥតបុគ្គលណាប្រៀបផ្ទឹមស្មើបាន
ទោះបីព្រះអង្គបានចូលនិព្វាន  តែព្រះទ្រង់ញាណបានប្រតិស្ថាន ។
វិសុទ្ធវាទគឺធម៌វិន័យ  ប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធ
វិមហាគុណព្រះភគវន្ត  ដ៏វិសេសធ្ងន់ពិតប្រាកដមែន ។
និងព្រះពុទ្ធរូបដែលស្នងព្រះអង្គ  បានប្រថាប់គង់នៅគ្រប់ទីឋាន

សារីរិកធាតុល្អស្អាតកល្យាណ បានប្រតិស្ថានប្រទេសតូចធំ ។
ហេតុនេះសូមព្រះពុទ្ធដ៏មានបុណ្យ មេត្តានិមន្តសង្គ្រោះយើងខ្ញុំ
ទទួលនូវគ្រឿងសក្ការៈឧត្តម ដែលបានរៀបចំមាឃបូជា ។
ដោយគុណតេជៈនៃព្រះបារមី មាឃបុណ្ណមីក្សេមក្សាន្តសុខា
សន្តិស្រោចស្រប់សព្វដែនឋានា មនុស្សសត្វទេព្តាបានវឌ្ឍនា ។
ដើម្បីនឹងបានផលានិសង្ស ដល់ខ្ញុំព្រះអង្គបរិស័ទគ្រប់គ្នា
ប្រកបដោយសុខចំរើនគ្រប់គ្រា រួចចាកទុក្ខាដល់និព្វានហោង ។

# ប្រែជាពាក្យកាព្យមួយបែបទៀត

ព្រះមានព្រះភាគអង្គឯណា ទ្រង់ព្រះនាមថាព្រះគោតម
កំចាត់កិលេសទាំងតូចធំ មិនឱ្យរួបរុំសន្តាននៅ ។
ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ឥតគ្រូដទៃប្រៀនប្រដៅ
ទ្រង់មានចរិយាឥតហ្មងសៅ ករុណាឆ្ពោះទៅសត្វគ្រប់គ្នា ។
នឹងបញ្ញាគុណចាក់ធ្លុះធ្លាយ ជ្រៅឆ្ងាយទូលាយអនន្តា
ព្រះអង្គជាគ្រូក្នុងលោកា ឥតមានគ្រូណាប្រៀបផ្ទឹមបាន។
ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាទីកលន្ទនិវាបស្ថាន
ជិតក្រុងរាជគ្រឹះដែនបូរាណ ដែលប្រាកដមានក្នុងមគធា ។
ភិក្ខុអរហន្តដ៏ពណ្ណរាយ ពាន់ពីររយបួយហាសិបណា
ចូលទៅគង់គាល់នៅត្រៀបត្រា តបដោយនាថាដ៏ឧត្តម ។
ហើយទើបព្រះអង្គទ្រង់សន្និបាត សំដែងឱវាទបាតិមោក្ខសម
ចំពោះភិក្ខុសង្ឃដ៏ឧត្តម ដែលមកជួបជុំនៅពេលនោះ ។
ជាសាសនានៃព្រះពុទ្ធម្ចាស់ គ្រប់អង្គតែងត្រាស់ឥតមានមោះ
យ៉ាងសង្ខេបខ្លីល្អពិរោះ ដាយគាថានោះតែបីបទ ។
ក្នុងថ្ងៃពេញបូណ៌មីមាឃា កបនក្ខត្តាល្អប្រាកដ
ហើយប្រជុំភិក្ខុកំណត់ ទ្រង់សម្តែងបទវិនយា ។
ជាច្បាប់សំរាប់ភិក្ខុខ្មី ពោលគឺបាលីបាតិមោក្ខា

| | | |
|---|---|---|
| មានអត្ថបរិសុទ្ធដ៏ថ្លៃថ្លា | សូត្រឧបោសថាថ្ងៃបុណ្ណមី | ។ |
| មួយទៀតកាលអង្គព្រះសុគត | សំរេចឥរិយាបថក្រុងវេសាលី | |
| មានភិក្ខុចោមរោមជាប្រក្រតី | ទ្រង់ប្រាប់សេចក្តីឱ្យដឹងបាន | ។ |
| ថានៅតែបីខែទៀតទេ | ទ្រង់នឹងបែករេចូលនិព្វាន | |
| បរិស័ទទាំងពួងយើងខ្ញុំមាន | ក្តីជ្រះថ្លាបានទាន់ធម៌គ្រប់ | ។ |
| យើងខ្ញុំសូមរំលឹកព្រះសម្ពុទ្ធ | និងសង្ឃជាបុត្រខីណាស្រព | |
| និព្វានកន្លងយូរថ្ងៃយប់ | នឹកមិនមានឈប់ដោយជ្រះថ្លា | ។ |
| យើងខ្ញុំបានដល់នក្ខត្តឫក្ស | មង្គលអ៊ឹកធឹកធំណាស់សា | |
| បាននាំគ្នាធ្វើសក្ការា | ទៀនធូបជាអាទិ៍តាមប្រឹងប្រែង | ។ |
| យើងខ្ញុំមានចិត្តត្រេករីករាយ | ជួបជុំខ្វល់ខ្វាយទីនេះឯង | |
| ដើម្បីសក្ការៈតាក់តែង | បូជាកោតក្រែងដោយផ្ចិតផ្ចង់។ | |
| សូមថ្វាយបង្គំសូមបូជា | ឆ្ពោះព្រះភគវាសាវ័កសង្ឃ | |
| តាមកាលឆ្ពោះភក្រ្តនៃព្រះអង្គ | និព្វានយូរលង់នោះហើយក្តី | ។ |
| កាលដែលសម្តែងព្រះបាតិមោក្ខ | ខែមាឃមានជោគបុណ្ណមី | |
| ព្រះច័ន្ទចាំងចែងរឿងរង្សី | ឧបោសថពិសីបរិសុទ្ធា | ។ |
| ដោយបុណ្យបូជាតាមសទ្ធា | សួស្តីសោភាមានគ្រប់គ្រា | |
| សាសនាសាស្តាយើងរាល់គ្នា | ថ្កុំថ្កើងថិរាយូរអង្វែង | ។ |

# គាថាប្រារព្ធវិសាខបូជា

| | |
|---|---|
| **វិសាខបុណ្ណមាយំ យោ** | **ជាតោ អន្តិមជាតិយា** |
| **បត្តោ ច អភិសម្ពោធឹ** | **អថោបិ បរិនិព្វុតោ** |
| **លោកេ អនុត្តរោ សត្ថា** | **ទយាញាណន្តជាសយោ** |
| **នាយកោ មោក្ខមគ្គស្ស** | **តិវិធត្ថុបទេសកោ** |

**មហាការុណិកំ នាថំ មយន្តំ សរណំ គតា**
**អាមិសេហិ ច បូជេន្តា ធម្មេហិ បដិបត្តិយា**
**ឥមន្នានិ សុនត្ថុត្តំ អតិមង្គលសម្មតិ ។**

វីរអង្គសម្ពុទ្ធជាម្ចាស់ឯណា ប្រពៃថ្លៃថ្លាអស្ចារ្យក្នុងលោក
ក្នុងជាតិជាទីបំផុតឥតរក អ្នកណាមានជោគស្មើនឹងព្រះអង្គ ។
ដែលទ្រង់ប្រសូតនៅក្រោមដើមរាំង ជាអស្ចារ្យខ្លាំងក្នុងលោកទាំងបី
ក្នុងថ្ងៃសុក្រជាពារពេញបូណ៌មី ខែវិសាខនៃរវាងឆ្នាំច ។
លុះព្រះជន្មម្ភៃប្រាំបួនហើយក៏ ទ្រង់យាងចេញចរទៅបព្វជ្ជា
កណ្តាលអធ្រាត្រថ្ងៃពេញបុណ្ណមា ខែអាសាធនាវរវាងឆ្នាំថោះ ។
លុះព្រះជន្មសាមសិបប្រាំទ្រង់ត្រាស់ ដឹងសព្វគ្មានខ្វះជាសព្វញ្ញូ
ក្នុងថ្ងៃពុធពិតជាថ្ងៃពេញបូណ៌ ខែវិសាខានាឆ្នាំរកា ។
ហើយជាគ្រូធំលើមនុស្សទេវតា ឥតមានសាស្តាដទៃផ្ទឹមបាន
ទ្រង់មានករុណានិងបញ្ញាញាណ ជ្រាលជ្រៅដូចស្ថានមហាសមុទ្រ។
នឹងអធ្យាស្រ័យមិនរើសមុខមាត់ ទ្រង់យាងនាំសត្វក្នុងផ្លូវនិព្វាន
ហើយទ្រង់សំដែងសេចក្តីទូន្មាន បីប្រការបានគ្រប់ពួកបរិស័ទ ។
លុះដល់ព្រះអង្គព្រះជន្មកំណត់ ប៉ែតសិបឆ្នាំគត់ទ្រង់ចូលនិព្វាន
លើផែនថ្មធំឧត្តមក្បែមក្សាន្ត ក្រោមដើមរាំងដែនកុសិនារា ។
ក្នុងថ្ងៃអង្គារពារពេញបុណ្ណមា នៃវិសាខារវាងឆ្នាំម្សាញ់
យើងខ្ញុំទាំងឡាយមិនមានកំណាញ់ ជឿស្មោះអស់អញក្នុងការកុសល។
សូមដល់ព្រះពុទ្ធព្រះអង្គតម្កល់ ព្រះទ័យខ្វាយខ្វល់ករុណាដល់សត្វ
អង្គនោះថាជាទីពឹងប្រាកដ ស្មើដោយជីវិតឥតពឹងដទៃ ។
ហើយសូមបូជាដោយគ្រឿងប្រពៃ តាមពាក្យបាលីហៅថាអាមិស
នឹងដោយនូវធម្មបូជានេះ ប្រតិបត្តមិនខុសក្នុងព្រះធម៌ឡើយ ។
យើងខ្ញុំទាំងឡាយឱនកាយថ្វាយហើយ ចិត្តពុំកន្តើយក្រេបយកប្រយោជន៍
ចំពោះមគ្គផលដល់ទៅបរលោក សូមអោយមានជោគគ្រប់ជាតិទៅហោង ។

# វិសាខបូជាវណ្ណនា

ថ្ងៃនេះប្រចួបចំខួបតិថី    វិសាខបុណ្ណមីនៃព្រះវិជិត
ប្រសូត,ត្រាស់ដឹងនិងនិព្វានពិត    កំចាត់ងងឹតចេញពីក្នុងលោក ។
យើងខ្ញុំទាំងឡាយជាពុទ្ធសាសន៍    ធ្វើសក្ការៈតាមដោយប្រយោគ
គោរពបូជាដល់ព្រះមានជោគ    ប្រកបអធិយោគសន្សំកុសល ។
ថ្ងៃនេះឯងហើយព្រះពុទ្ធជិនស្រី    គង់ក្រោមរស្មីចន្ទ្រានិម៌ល
នៅទៀបឆ្នេរនេរញ្ជរាជល    ទសពលផ្ចាលផ្ចាញ់ពួកមារចង្រៃ។
ថ្ងៃនេះជាថ្ងៃជោគជ័យបវរ    ដល់សត្វនិករទូទាំងភពត្រៃ
ព្រះពុទ្ធប្រទាននូវប្រទីបថ្លៃ    ទុកដល់សព្វថ្ងៃគ្រប់ទីនានា ។
យើងខ្ញុំទាំងអស់ជាពុទ្ធបរិស័ទ    បានមកប្រណិប័តន៍ប្រជុំគ្នីគ្នា
រៀបគ្រឿងប្រដាប់សក្ការបូជា    មានទៀនធូបផ្កាលំឧតផ្ចិតផ្ចង់ ។
ដោយចិត្តជ្រះថ្លាយ៉ាងច្បាស់ប្រត្យក្ស    ជំនឿជឿជាក់ក្នុងព្រះពុទ្ធអង្គ
មានព្រះពុទ្ធរូបតាងស្នងព្រះអង្គ    ទ្រង់ស្ដេចមកគង់ប្រថាប់ថ្លៃថ្លា ។
យើងខ្ញុំសូមថ្វាយសក្ការបូជា    គោរពវន្ទាព្រះត្រៃរតនា
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃមហិមា    ដោយកាយវាចានិងចិត្តប្រពៃ ។
បពិត្រព្រះពុទ្ធព្រះទសពល    វិជិតនិម្មលនាមាភិធេយ្យ
មានឫទ្ធិតេជៈគុណព្រះបារមី    ល្បាញល្បីសុសសាយក្នុងលោកត្រៃភព។
ទ្រង់ជាបូជារហបុគ្គល    បញ្ញាញាណយល់ដឹងទាំងគ្រប់សព្វ
ព្រះធម៌ព្រះអង្គដ៏វិសេសគាប់    ប្រព្រឹត្តបានស្ងប់រម្ងាប់ទុក្ខបាន ។
ព្រះពុទ្ធជាគ្រូនៃមនុស្សទេព្ដា    ឥតបុគ្គលណាប្រៀបផ្ទឹមស្មើបាន
ទោះបីព្រះអង្គបានចូលនិព្វាន    តែព្រះទ្រង់ញាណបានប្រតិស្ថាន ។
វិសុទ្ធវាទគឺធម៌វិន័យ    ប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធ
រីមហាគុណព្រះភគវន្ត    ដ៏វិសេសធ្ងន់ពិតប្រាកដមែន ។
និងព្រះពុទ្ធរូបដែលស្នងព្រះអង្គ    បានប្រថាប់គង់នៅគ្រប់ទីថាន
សារីរិកធាតុល្អស្អាតកល្យាណ    បានប្រតិស្ថានប្រទេសតូចធំ ។

ហេតុនេះសូមព្រះពុទ្ធដ៏មានបុណ្យ មេត្តានិមន្តសង្គ្រោះយើងខ្ញុំ
ទទួលនូវគ្រឿងសក្ការៈឧត្តម ដែលបានរៀបចំវិសាខបូជា ។
ដោយគុណតេជៈនៃព្រះបារមី វិសាខមុណ្ណមីក្សេមក្សាន្តសុខា
សន្តិស្រោចស្រប់សព្វដែនឋានា មនុស្សសត្វទេព្តាបានវឌ្ឍនា ។
សូមឱ្យប្រទីបដែលល្អពណ្ណរាយ បំភ្លឺសុះសាយសព្វទ្វីបលោកា
ឱ្យសត្វឆ្លងផុតវដ្តសង្សារ សមដូចប្រាថ្នាគ្រប់គ្នាទៅហោង ។

## នមស្សការ បទបឋ្យាវត្ត

**នមោ អរហតោ សម្មា សម្ពុទ្ធស្ស មហេសិនោ**
សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្តកាលស្វែងរកធម៌
គឺពោធិញ្ញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។
**នមោ ឧត្តមធម្មស្ស ស្វាក្ខាតស្សេវ តេនិធ**
សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសំដែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកក្នុងសាសនា ។
**នមោ មហាសង្ឃស្សាបិ វិសុទ្ធិសីល ទិដ្ឋិនោ**
សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទិដ្ឋិនិងសីល
ឱ្យបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។
**នមោ ឱមាត្យារទ្ធស្ស រតនត្តយស្សសាធុកំ**
សូមថ្វាយបង្គំប្រជុំត្រៃរត្ន ប្រារព្ធដោយបទមាន៣ប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យថ្លឹងថ្លែងពុំបាន ។
**នមោ ឱម កាតីតស្ស តស្ស វត្ថុត្តយស្សបិ**
សូមថ្វាយបង្គំភ្លំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វឋាន វិសេសកល្យាណដោយគុណគួរគាប់។
**នមោ ការប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា**

សូមថ្វាយបង្គំត្រ័យរត្នសោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកំចាត់ ធ្វើក្តីវិបត្តិឱ្យស្ងាត់សូន្យទៅ ។
**នមោ ការានុភាវេន សុវត្ថិ ហោន្តុ សព្វទា**
សូមថ្វាយបង្គំត្រ័យរត្នទាំងបី សូមសុខសួស្តីកើតសព្វវេលា
ដោយអានុភាពធ្វើការវន្ទា គោរពបូជាឆ្ពោះព្រះត្រៃរត្ន ។
**នមោ ការស្សតេជេន ជិនិម្ហិ ហោមិ តេជវា**
សូមថ្វាយបង្គំត្រៃរត្នសោភា តេជៈចេស្តាចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ តេជៈបុណ្យធំសូមកើតមានហោង ។

## បទសូត្ររំលឹកគុណទាំង៦កាល

### បទព្រហ្មគិត

ខ្ញុំសូមរំលឹកគុណ សរសើរបុណ្យព្រះជិនស្រី
កាលស្តេចចាប់បដិ- សន្ធិផ្ទៃព្រះមាតា ។
បវរព្រះកន្លេង មាតាហោងឆ្នាំរការ
នៅខែអាសាធណា ថ្ងៃព្រហស្បតិ៍ពេញបូណ៌មី ។
នាកាលពោធិសត្វ ប្រសូតថ្ងាត់ចេញចាកផ្ទៃ
នៅឆ្នាំចខែពិ- សាខពេញបូណ៌ថ្ងៃសុក្រណា។
វេលានាថ្ងៃត្រង់ ក្សិណនោះអង្គព្រះមាតា
ទើបប្រសូតពោធិ- សត្វសោភីកណ្តាលផ្លូវ ។
ឈោងចាប់មែករុក្ខា សាលព្រឹក្សាត្រានោះកូវ
កាលព្រះនាងយាងទៅ កាន់នគរព្រះបិតា ។
មានហេតុអស្ចារ្យក្រៃ កាលនោះនៃរាជកុមារ
យាងទៅទិសឧត្តរា បានប្រាំពីរជំហានកូវ ។
កាលសោយរាជ្យសម្បត្តិ នោះជាក់ក្តាត់នៅឆ្នាំឆ្លូវ
ខែកត្តិកនិត្យនៅ ពេញបូណ៌មីថ្ងៃអាទិត្យ ។
នាកាលពោធិសត្វ ស្តេចទ្រង់កាត់ព្រះទ័យគិត

ចេញសាងព្រះផ្នួសពិត　　នៅឆ្នាំថោះខែអាសាធ ។
ព្រហស្បតិ៍ពេញបូណ៌មី　　នាកណ្ដាលលរាត្រីស្ងាត់
ព្រមដោយឆន្នអាមាត្យ　　ដង្ហែអង្គព្រះពោធិ៍ ។
កាលត្រាស់ឆ្នាំរការ　　ពិសាខាពេញបូណ៌មី
ថ្ងៃពុធប្រាកដខ្ចី　　ព្រះបាលីនិទានចេញ ។
នាកាលព្រះទ្រង់ញាណ　　ចូលនិព្វានឆ្នាំម្សាញ់
នៅខែពិសាខពេញ　　បូណ៌មីថ្ងៃអង្គារ ។
ក្រោមសាលព្រឹក្សទាំងគូ　　ទៀបនគរកុសិនារា
ហៀបបែកបច្ចុសា　　ព្រះភគវាស្ដេចនិព្វាន ។
ខ្ញុំសូមនមស្សការ　　ដោយវាចាកាយចិត្តថ្កាន
រំលឹកគុណទ្រង់ញាណ　　ចំពោះកាលទាំងប្រាំមួយ ។
មុននឹងចូលនិព្វាន　　ទ្រង់ប្រទានធម៌ទុកឱ្យ
បរិស័ទនៅឯក្រោយ　　ប្រតិបត្តិតាមគ្រប់ៗគ្នា ។
ប្រាំបីម៉ឺនបួនពាន់　　នៃព្រះធម្មក្ខន្ធា
ព្រមទាំងទុកសាសនា　　ប្រាំពាន់ព្រះវស្សាហោង ។
តេជៈផលានិសង្ស　　លើកកំបង់អញ្ជលីផ្សង
សូមឱ្យខ្ញុំបានឆ្លង　　ផុតពីទុក្ខសោករោគភ័យ ។
សូមទាន់ព្រះសិអារ្យ　　បានត្រាស់នាខាងមុខនៃ
ចម្លងសត្វប្រុសស្រី　　ដាក់ដល់ត្រើយនិព្វាននាយ ។
ព្រះអង្គទ្រង់ទេសនា　　ប្រោសសត្តាផងទាំងឡាយ
ឱ្យរួចពីអបាយ　　ភូមិទាំងបួនពិតប្រាកដ ។
ខ្ញុំសូមបានមគ្គផល　　សម្រេចដល់ព្រះអរហត្ត
ឆ្លងផុតសង្សារវដ្ដ　　សមដូចចិត្តប្រាថ្នាហោង ។

# អដ្ឋមហាឋាន

**បឋមំ លុម្ពិនីជាតំ　　ទុតិយំ ពោធិមុត្តមំ**
**តតិយំ ធម្មចក្កញ្ច　　ចតុត្ថំ បាលិលេយ្យកំ**
**បញ្ចមំ ច នាឡាគិរី　　ឆដ្ឋមំ បាដិហារិយំ**
**សត្តមំ សិរិទេវិញ្ញ　　អដ្ឋមំ បរិនិព្វុតំ**
**ឯតេ អដ្ឋ មហាឋានា　　ជម្ពុទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ　　អហំ វន្ទាមិ ទូរតោ ។**

ឋានធំទាំងឡាយប្រាំបីកន្លែង　　ជាទីស្ងប់ស្ងែងដល់ពពួកសត្វ
ទី១ ឧទ្យានជាឋានព្រៃស្វាត់　　គឺព្រៃសាលវ័តន៍ដែលទ្រង់ប្រសូត ។
ទី២ ប្រសើរដែលព្រះទ្រង់ស្រូត　　ត្រាស់ក្រោមដើមពោធិព្រឹក្សឧត្តម
ទី៣ កន្លែងដែលព្រះបរម　　សំដែងព្រះធម្មឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុប្រាំអង្គគឺបញ្ចវគ្គ-　　គឺយ័ដែលជាអ្នកបម្រើព្រះអង្គ
ដោយព្រះទ័យថ្លៃមិនអាចលះបង់　　ហើយយាងតម្រង់ពីដើមព្រៃទៅ ។
ទី៤ គឺទីដែលទ្រង់គង់នៅ　　ក្នុងឋានព្រៃជ្រៅឈ្មោះបាលិលេយ្យ
ទីនោះគ្មានមនុស្សមានតែសត្វព្រៃ　　គឺដំរីថ្លៃបម្រើព្រះអង្គ ។
ទី៥ គឺទីដែលព្រះពុទ្ធអង្គ　　ផ្ចាញ់សត្វទ្រនង់នាឡាគិរី
ទីនោះមានមនុស្សបែកពួកជាទ្វី　　ទៅមើលពិធីនៃព្រះសម្ពុទ្ធ ។
ទី៦ កាលព្រះសព្វញ្ញុត-　　ញ្ញាណជាមកុដត្រៃលោកាចារ្យ
ផ្ចាញ់ពួកនិគ្រន្ថដោយបាដិហារ្យ　　ឈ្មោះល្បីអស្ចារ្យគ្មាននរណាដល់។
ទី៧ កាលព្រះទសពល　　គង់លើមណ្ឌលថ្មព្រះឥន្ទ្រា
ទ្រង់បានសំដែងនូវព្រះធម្មា　　ប្រាកដនាមថាធម៌អភិធម្ម ។
សងគុណមាតាដែលមានគុណធំ　　លើព្រះបរមសម្ពុទ្ធថ្លៃថ្លា
ទី៨ កាលអង្គព្រះសាស្តា　　ផ្ទំក្រោមដើមសាលព្រឹក្សទាំងគូរ។
ពេលនោះឯងហើយព្រះសព្វញ្ញូ　　ព្រះអង្គជាគ្រូយាងចូលនិព្វាន
ឋានធំប្រាំបីកន្លែងនោះមាន　　ទ្រង់ប្រតិស្ឋានជម្ពូទ្វីបា ។
ជាទីដែលពួកមនុស្សនិងទេព្តា　　មានចិត្តជ្រះថ្លាគួរទៅយង់យល់

ខ្ញុំសូមឱនកាយបង្គំឆ្ពោះដល់ ឋានធំនិមលប្រាំបីនោះឯង ។
សូមឱ្យខ្ញុំបានដល់ឋានសួគ៌ា ដូចក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត
មានព្រះនិព្វានជាអវសានជាតិ កុំឱ្យខ្ញុំឃ្លាតពីនិព្វានហោង ។

## ព្រះត្រៃលក្ខណ៍

រូបំ ទុក្ខំ ទុក្ខអើយទុក្ខខ្លាំង ខ្លាំងពន់ប្រមាណ ពីតូចដល់ធំ
ទុក្ខទំក្នុងប្រាណ ទុក្ខឥតស្រាកស្រាន្ត ទុក្ខដល់ខ្លួនក្ស័យ ។
អនិច្ចំពុំឋិត ពុំថេរនៅនិត្យ យឺនយូរឡើយនៃ ស្លាប់ទៅជាខ្មោច
អសោចពេកក្រៃ ឆ្អឹងសាច់សរសៃ ជាព្រះធរណី ។
អនត្តាសូន្យសោះ សូន្យរូបសូន្យឈ្មោះ សូន្យសព្វសញ្ញី សូន្យយសសក្តា-
ធិការសោភី សូន្យសព្វឥន្រ្ទីយ៍ មាសប្រាក់អន្តរាយ ។
ដូច្នេះគួរគិត គួររក្សាចិត្ត ខឹងឆាប់រសាយ ចិត្តស្លូនទន់ទាប
ដូចកូននិងម្តាយ ខឹងឆាប់រសាយ បាត់ខឹងទៅហោង ។
គួរកុំបីខ្ជិល កសាងទានសីល និងភាវនាផង រៀនធម៌វិន័យ
ប្រពៃកន្លង ពីក្មេងទៅហោង កុំចាំដល់ចាស់ ។
ដល់ពេលជិតស្លាប់ ទើបបានប្រញាប់ ប្រវាខ្វេសខ្វាស់ រកធម៌ឱ្យជួយ
ព្រោះព្រួយខ្លាំងណាស់ នោះមិនបានច្បាស់ ដូចនៅក្មេងឡើយ ។
គួរហាត់លះចិត្ត អកុសលទុច្ចរិត បង្ការឱ្យហើយ ដល់ពេលជិតស្លាប់
ឈោងចាប់កោះត្រើយ ទីពឹងនោះហើយ បានដូចប្រាថ្នា ។
ផលការហាត់ចិត្ត រឿយៗល្អពិត នឹងជួយអាត្មា ឱ្យបានសម្បត្តិ
ល្អក្តាត់ណាស់ណា ជាមនុស្សទេព្តា នៅលោកិយបាន ។
ហើយនឹងបានដល់ លោកុត្តរផល សម្រេចនិព្វាន ក្នុងជាតិបំផុត

ចំហុតមែនមាន ដោយបារមីញាណ សាងទុកនោះហោង ។

## បច្ឆិមពុទ្ធវចនៈ

យោ វៅ អានន្ទអើយ នែបាអើយមកអាយរ៉ា
តថាគតនឹងមរណា ចាកចោលបាមិនខានឡើយ ។
ចូរបានៅនៅឱ្យសុខ កុំជាទុក្ខណាបាអើយ
តថាគតលាអ្នកហើយ កុំសោកឡើយណាអានន្ទ ។
អង្គអញតថាគត នឹងរលត់អស់បញ្ចក្ខន្ធ
នៅចុះណាអានន្ទ ខំគ្នេគ្នាន់ក្នុងអង្គប្រាណ ។
ខ្លួនអ្នកនៅសព្វថ្ងៃ មានឧបមេយ្យដូចជាចាន
មិនស្ថិតស្ថេរប៉ុន្មាន គង់នឹងបានវិនាសទៅ ។
ហេតុនេះបាអានន្ទ ចូរគ្នេគ្នាន់គិតឱ្យជ្រៅ
ឥតពីតថាគតទៅ អ្នកឯងនៅថែសាសនា ។
សាសនាតថាគត ស្ថិតប្រាកដនឹងអ្នកណា
ដែលមានចិត្តជ្រះថ្លា ប្រព្រឹត្តត្រូវតាមលំអាន ។
ក្រានេះតថាគត នឹងរលត់ខន្ធនិព្វាន
ដោយជរាចូលរុករាន ទន្ទ្រានមកផ្ដាច់សង្ខារ ។

## បរិនិព្វានគាថា

ដំណាលកាលអង្គព្រះទ្រង់ញាណ យាងចូលនិព្វានគ្មានកម្រិត
ក្រោមដើមសាលព្រឹក្សព្រៃជុំជិត បរិស័ទមូលមិត្រពេញត្រៀបត្រា ។
នៅថ្ងៃអង្គារ ១៥កើត ក្នុងខ្មែតវិសាខនៃមាសា
ឆ្នាំម្សាញ់បញ្ចស័កយាមអង្គារ វេលាព្រឹកព្រាងស្វាងរស្មី ។
ថេរានុថេរទាំងចាស់ក្មេង លើកលែងតែអង្គអរហន្តថ្លៃ
ពេលនោះយោបំយំពេកក្រៃ ស្ដាយព្រះជិនស្រីគ្រប់ៗគ្នា ។
ខ្លះស្ដាយធ្លាប់ស្ដាប់ច្បាប់ឱវាទ ខ្លះស្ដាយបិណ្ឌបាតតាមធម្មតា

ខ្លះស្តាយធ្លាប់ស្តាប់ធម៌ទេសនា គ្រប់គ្នាទាំងអស់គ្មានសេសសល់ ។
ក្នុងព្រៃសាលវ័ន្តលាន់រំពង គឹកកងទាំងអស់សព្វសាកល
ផ្ការាំងជំរុះជ្រុះជាផល ថ្វាយដល់ព្រះមុនិន្ទពិនលោកា ។
លុះដល់គ្រាក្រោយព្រះអានន្ទ និមន្តបិណ្ឌបាតតាមតាមធម្មតា
អ្នកស្រុកស្រីប្រុសទាំងអស់គ្នា បង្គំវន្ទាយំសួរសព្វ ។
បិត្រលោកម្ចាស់ឈ្មោះអានន្ទ ចុះអង្គព្រះអរហន្តព្រះចមភព
បាត់អង្គសាស្តាទាំងថ្ងៃយប់ ចមភពតើស្តេចយាងទៅណា ។
យើងខ្ញុំធ្លាប់បានឃើញលោកម្ចាស់ ជាមួយនឹងព្រះសព្វវេលា
ថ្ងៃនេះបាត់អង្គព្រះឈ្មោះមារ មិនឃើញសាស្តាស្តេចយាងមក ។
អានន្ទមិនធន់ទន់ព្រះទ័យ ឮអស់ប្រុសស្រីស្តីសួររក
អង្គព្រះសាស្តាមិនឃើញមក អានន្ទយកហត្ថខ្ទប់ភក្ត្រា ។
ញោមអើយម្តេចព្រះអង្គទ្រង់ញាណ យាងចូលនិព្វានទៅហើយណា
បានជាបាត់អង្គព្រះសាស្តា ឃើញតែអាត្មាម្នាក់ឯងនៅ ។
ញោមអើយកម្មកាចរបស់យើង ឱ្យយើងព្រាត់ប្រាស់ព្រះចមចៅ
ព្រះលោកនាថនិព្វានទៅ យើងសែនសោកសៅក្នុងចិន្តា ។

## និព្វានសូត្របទពាក្យ៧

កាលអង្គសម្តេចព្រះទ្រង់ញាណ ស្តេចចូលនិព្វានមានអស្ចារ្យ
ក្នុងដែនមល្លរដ្ឋកុសិនារា លើផែនថ្មដាម្លប់សាលព្រឹក្ស ។
ក្នុងឆ្នាំម្សាញ់វិសាខា ពេញបូណ៌អង្គាររល្អពន្លឹក
រាត្រីខ្សោយហើយពេលទៀបព្រឹក ព្រះអង្គទ្រង់នឹកដល់និព្វាន ។
បច្ចូសម័យថ្ងៃជិតរះ ស្តេចទ្រង់បិទព្រះឱស្ឋចូលនិព្វាន
ចេញហើយចូលទៀតទើបនិព្វន និរោធក្នុងឈានជាចន្លោះ ។
នៃឈានទី៤និងទី៥ កើតអស្ចារ្យមាំក្នុងគ្រានោះ
លោកធាតុទាំងហ្មឺនញ័រដូចគោះ ទៅខាងលើនោះដល់ស្ថានព្រហ្ម
ខាងក្រោមដល់រងបាតធរណី ញាប់ញ័រគ្រប់ទីស្ថានតូចធំ

ពួកមនុស្សទេវតាមារឥន្ទព្រហ្ម    ទួញសោកស្រែកយំស្តាយសាស្តា ។
ពេលនោះមានផ្កានាគបុស្ស    ជ្រុះរោយរាយចុះចាកសួគ៌ា
ទេវតានាំមកបាចបូជា    ព្រះសពភគវាជាអស្ចារ្យ ។
សហម្បតីព្រហ្មសរសើរ    ថាផុតដំណើរភពសង្សារ
ព្រះអង្គឈ្នះពួកបញ្ចមារ    ស្តេចដាក់សង្ខារចូលនិព្វាន ។
ព្រះឥន្ទពោលថាអនិច្ចា    សត្វក្នុងលោកាមិនទៀងប្រាណ
អម្បាលតួអង្គព្រះទ្រង់ញាណ    គង់ចូលនិព្វានដូចនេះណា ។
អនុរុទ្ធថាព្រះតថាគត    ផុតខ្យល់រលត់អស្សាសា
បស្សាសៈគ្មានសល់ត្រង់ណា    ដូចលត់ជ្វាលាឥតនៅឡើយ ។
អានន្ទពោលថាព្រះសម្ពុទ្ធ    ស្តេចនិព្វានផុតភពទៅហើយ
មានហេតុអស្ចារ្យខ្លាំងពេកក្រៃ    មានក្នុងហឫទ័យនិងកាយា ។
មនុស្សទេវតាព្រាហ្មណ៍និងពួកក្សត្រ    ក៏កើតវិបត្តិសោយសោកា
វៀរលែងតែអង្គអរហន្តា    យំស្តាយសាស្តាព្រះទ្រង់ញាណ ។
ឱ!ព្រះសម្ពុទ្ធមកុដត្រៃលោក    ម្តេចឡើយទ្រង់ជោគចូលនិព្វាន
ចោលពួកបរិស័ទច្រើនសែនលាន    នរណាទូន្មានជួសព្រះអង្គ ។
យើងខ្ញុំជ្រកក្រោមម្លប់សាសនា    សង្ឃឹមសាស្តាជួយស្រោចទ្រង់
ដោយសារភេត្រាធម៌ព្រះអង្គ    ម្តេចឡើយក៏ទ្រង់និព្វាននេះ ។
ស្តាយអើយស្តាយអង្គព្រះទ្រង់ញាណ    មិនគួរនិព្វានអ្វីឆាប់ម្ល៉េះ
ស្តាយណាស់ថ្លើមស្អួតស្ទើររបេះ    ទ្រូងតឹងស្ទើរប្រេះទៀបមរណា ។
ស្តាយអើយស្តាយទ្រង់ធ្លាប់ប្រទាន    ពុទ្ធដិកាទូន្មានយើងរាល់គ្នា
ស្តាយធ្លាប់ថ្វាយទាននឹងសាស្តា    ស្តាយស្តាប់ទេសនាផ្ទាល់ព្រះអង្គ ។
ស្តាយអើយសែនស្តាយព្រះកាយទ្រង់    សាវ័កធ្លាប់គង់គាល់រហង់
ទ្រង់ជាប្រធាននៃពួកសង្ឃ    ឥឡូវព្រះអង្គនិព្វានបាត់ ។
ឱ!ស្តេចមច្ចុមារកំណាច    ម្តេចឡើយមិនខ្លាចហ៊ានមកកាត់
ព្រះជន្មព្រះពុទ្ធដូចសព្វសត្វ    ឱ្យនិព្វានបាត់ទៅស្ងាត់ឈឹង ។
គ្មានចិត្តអាណិតចិត្តមេត្តា    គ្មានចិត្តករុណាធ្វើយ៉ាងហ្នឹង

គ្មានគិតយោគយល់ថាទីពឹង ជាទីពុំនឹងយើងរាល់គ្នា ។
យើងខ្ញុំព្រះអង្គបាត់ទ្រង់ជោគ បីដូចផ្ទៃលោកបាត់សុរិយា
មានតែងងឹតឥតភ្លឺថ្លា ព្រោះម្ចាស់សាសនានិព្វានហើយ ។
យើងខ្ញុំអ្នកតែងនឹងថ្លែងគុណ សូមតេជៈបុណ្យបានដល់ត្រើយ
ជួយឱ្យទុក្ខភ័យរោគសះស្បើយ ដរាបដល់ត្រើយនិព្វានហោង ។

## ទំនួញអានន្ទ

ដំណាលកាលអង្គព្រះសម្ពុទ្ធ ស្ដេចទ្រង់បរិសុទ្ធិសួរប្រស្នា
ចំពោះអានន្ទឱ្យដោះសារ ហើយព្រះសាស្ដាស្ដេចនិព្វាន ។
ដើមហេតុអានន្ទភាន់សញ្ញា ពិលាបសោកាស្ដាយទ្រង់ញាណ
ដឹងច្បាស់ថាទ្រង់ចូលនិព្វាន អានន្ទគិតស្មានគ្មានទីពឹង ។
បរិទេវៈអ្នកទួញថា ឱព្រះសាស្ដាស្ដេចវិលវឹង
យាងចូលនិព្វានធ្យានសូន្យឈឹង អស់ទីពុំនឹងប៉ុណ្ណឹងហើយ ។
ឱ ព្រះសម្ពុទ្ធបំផុតលោក មានជោគតេជៈណាម្ចាស់អើយ
បើទ្រង់និព្វានបាត់ទៅហើយ ម្ចាស់អើយសមស្វាត់គ្រប់គ្នា ។
ដូចជាអានន្ទខ្ញុំនេះឯង ខានបានកោតក្រែងស្ដាប់ទេសនា
ព្រះរូបព្រះឆោមព្រះសាស្ដា ខានបានសិក្សាអាថ៌សេចក្ដី ។
ខានបានត្រង់ត្រាប់ច្បាប់ឱវាទ អង្គព្រះមុនីនាថដូចប្រក្រតី
ខានចរបិណ្ឌបាត្រតាមជិនស្រី ខានស្ដីខានស្ដាប់ធម៌ទេសនា ។
អានន្ទមិនទាន់សម្រេចពិត អស់កិច្ចបព្វជិតក្នុងសាសនា
ឥឡូវថ្ងៃនេះព្រះសាស្ដា ស្ដេចនឹងយាត្រាចូលនិព្វាន ។
បពិត្រចម្កុដវិសុទ្ធិវង្ស មិនគួរបើទ្រង់និងនិព្វាន
ចោលអស់បរិស័ទណាទ្រង់ញាណ យាងចូលកាន់ស្ថានបរមសុខា ។
ព្រះអង្គទ្រង់សួរអានន្ទមុន ដើម្បីជាគុណដ៏ថ្លៃថ្លា
បញ្ជាក់សេចក្ដីនៃពុទ្ធដីកា ដោយទ្រង់ប្រាថ្នាដោះការស្ដាយ ។
អានន្ទចូលអ្នកតាំងចិត្តទុក អ្នកកុំអផ្សុកចូលមកអោយ

យើងនឹងបញ្ជាក់ពីរូបកាយ បំណាច់អ្នកស្តាយកាយនេះឯង ។
អានន្ទអើយកាលព្រះបិតា និព្វាននោះណាមានជាក់ស្តែង
ពេលនោះគឺបាអានន្ទឯង ក៏បានឃើញស្តែងដោយន័យនា ។
សាវ័កអ្នកស្តាប់ពាក្យឱវាទ ចូលមកសន្និបាតពេញត្រៀបត្រា
អស់ពួកក្សត្រីយ៍នឹងក្សត្រា មកស្តាប់ទេសនាក្នុងគ្រានោះ ។
ក្សណនោះឯស្តេចបច្ចុរាជ អង្គអាចឈ្លានពានមិនពិគ្រោះ
ឥតកោតញញើតបន្តិចសោះ សង្កាត់ចំពោះព្រះអង្គារ ។
នាំយកជីវិតព្រះបិតុរង្គ មិនមានបង្អង់ពេលវេលា
ដោយឥតអៀនខ្មាស់អ្នករាល់គ្នា ពីគ្រានោះលុះដល់ឥឡូវ ។
ពេលនោះអស់ពួកញាតិវង្ស សឹងទ្រង់យោបំយំពេកកូវ
សោកស្តាយព្រះអង្គតែសព្វផ្លូវ ស្តេចត្រូវមរណៈធ្លាក់ជីវិត ។
តថាគតទេសន៍នាំពន្យល់ ប្រាប់ដល់ពួកញាតិនឹងទេព្វ
ដោយធម៌បីម៉ាត់កាត់ផ្តាច់ទី ធូលីប្រាស់ចាកស្រាកទុក្ខស្បើយ ។
ឯធម៌បីម៉ាត់គឺ អនិច្ចំ ទុក្ខំ អនត្តា អានន្ទអើយ
អ្នកភ្លេចបាត់សោះអស់ទៅហើយ ឬ មួយនៅឡើយឥតហ្មងសៅ ។
ចំណែកប៉ែកខាងធម៌វិន័យ គួរអ្នកកែខៃគិតឱ្យជ្រៅ
បើទុកជាយើងនិព្វានទៅ អ្នកនៅឯក្រោយក៏មិនអ្វី ។
ធម៌និងវិន័យថ្លៃវិសេស រម្ងាប់កិលេសបាបអប្រិយ៍
បើចិត្តអ្នកផ្ចង់ប្រុងស្មារតី មិនមែនក្រក្រីទេអានន្ទ ។
អានន្ទក្រាបទូលតបវិញថា ដែលទ្រង់ករុណាទោសស្រាលធ្ងន់
ប្រាប់ធម៌វិន័យច្រើនលើសលន់ អានន្ទចាំបានឥតភ្លាំងភ្លាត់ ។
ហេតុនេះអានន្ទមិនជិនណាយ ចេះតែនឹកស្តាយព្រះចម្កុដ
មិនចង់ឱ្យទ្រង់បែកប្រាស់ព្រាត់ ខ្វាយខ្វាត់ចោលខ្ញុំទេទសពល ។
ព្រោះធ្លាប់បានស្តាប់ទាំងយប់ថ្ងៃ អង្គព្រះចមត្រៃស្តេចពន្យល់
អោយបានដឹងសព្វកងកុសល ហេតុផលទាំងល្អអាក្រក់ផង ។
ទ្រង់ត្រាស់តបទៅព្រះអានន្ទ កុំឱ្យអាក់អន់ចិត្តសៅហ្មង

ព្រោះរូបយើងឯងមិនអាចឆ្លង កន្លងពីក្ដីស្លាប់មរណា ។
អានន្ទអើយរូបយើងក្មេងចាស់ តែងជួបប្រទះនឹងជរា
ម្ដេចអ្នកសោកស្ដាយកាយគ្រាំគ្រា មិនជាប្រយោជន៍ប៉ុន្មានឡើយ ។
កាយនេះប្រៀបបានរទេះចាស់ ដែលគេប្រើប្រាស់ឥតល្ហែល្ហើយ
អបស្ទបគ្រប់ពេលពុំមានស្បើយ គ្រាន់ហើយទើបបរត្រដរទៅ ។
តថាគតឯងក៏ដូច្នេះ អបស្ទបកាយនេះឱ្យគង់នៅ
ដោយឥទ្ធិបាទបួននោះកូវ បានជាគង់នៅដល់ទីនេះ ។
មួយទៀតធម៌ក្ដី វិន័យក្ដី អានន្ទកុំបីគិតសន្និះ
ថាក្រែងវិបត្តិស្ងាត់ត្រឹមណេះ អានន្ទផុតចេះត្រឹមណេះហើយ ។
មគ្គផលឥតមានកាលរារាំង ឃាត់ឃាំងនិស្ស័យនៃសត្វឡើយ
អំណើះឥតពីយើងទៅហើយ ធម៌វិន័យអើយជាគ្រូអ្នក ។
បរិស័ទទាំងបួនឯណាមួយ បានស្ងួយដម្កល់ចិត្តស្មោះស្នេហ៍គ្រ
ប្រតិបត្តិតាមធម៌សត្យាជាក់ តាមថ្នាក់ភេទភូមិរបស់ខ្លួន ។
បរិស័ទនោះឈ្មោះថាគោរព ឆ្ពោះព្រះចមភពយ៉ាងខ្ជាប់ខ្ជួន
ដោយការបូជាដ៏មាំមួន ត្រូវក្បួនបូជាដ៏ឧត្ដម ។
ឈ្មោះថារាប់អានតថាគត ប្រតិបត្តហ្មត់ចត់យ៉ាងសមរម្យ
អានន្ទអើយអ្នកកុំបីយំ គួរខំប្រតិបត្តិកាត់អវិជ្ជា ។
ចន្លោះពាក្យពោលព្រះសម្ពុទ្ធ ចម្កុដទ្រង់ផ្អាកការសន្ទនា
ទ្រង់បើកឱកាសពេលវេលា ដល់ភិក្ខុរាល់គ្នាសួរព្រះអង្គ ។
តែក្នុងរពលនោះភិក្ខុបរិស័ទ ស្ងៀមស្ងាត់រាល់គ្នាដោយស្ដាប់ទ្រង់
ហាក់បាត់ស្មារតីគ្រប់ៗអង្គ ទើបទ្រង់បញ្ជាក់សេចក្ដីថា ។
ហន្ទៈភិក្ខុទាំងឡាយអើយ យើងលាអ្នកហើយទាំងអស់គ្នា
មិនមានបង្អង់ពេលវេលា យើងនឹងគមនាចូលនិព្វាន ។
ត្បិតសង្ខារធម៌មិនទៀងទាត់ កើតហើយតែងភ្លាត់ជាមិនខាន
ឥតមានសង្ខារណាចៀសបាន កើតប្រាណមកហើយតែងប្រាស់ព្រាត់ ។
តុម្ហេ ហៃអស់លោកទាំងឡាយ ចូរខំខ្វល់ខ្វាយប្រុងប្រយ័ត្ន

កុំធ្វេសប្រហេសចូរខំហាត់ រៀនសូត្រហ្មត់ចត់ដោយប្រឹងប្រែង ។
ព្រោះថាធម៌ធ្វេសនេះជាធំ ជាគុម្ពជាគល់បាបនោះឯង
សត្វដែលធ្វើបាបបានឥតក្រែង ព្រោះធម៌ធ្វេសក្លែងខ្លាំងខ្លៀវក្លា ។
ម្យ៉ាងទៀតធម៌ធ្វេសនេះជាមូល អាចចាប់បញ្ចូលអស់សត្តា
អោយបាននាមឈ្មោះថាមរណា ប្រែថាធ្វើសត្វអោយកើតស្លាប់ ។
បញ្ចប់សេចក្ដីន័យដំណាល ពីកាលអានន្ទយំរៀបរាប់
សង្ខេបប៉ុណ្ណោះមិនបានជាប់ ដំណើររៀបរាប់ចប់ហើយហោង ។